# វិទ្យាស្ថាន ទូលេន
## គោលនយោបាយ និងច្បាប់ធនធានទឹក

## <u>សហគមន៍គោលដៅសំរាប់ការតាំងទីថ្មីនៅភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណា</u>

សេចក្តីសង្ខេបអំពីលំនៅដ្ឋាន[១]

បោះពុម្ពដើមដំបូងនៅឆ្នាំ ២០១៤




---


[១] និពន្ធនាយក ៖ Christopher Dalbom, ប្រធានកម្មវិធីនៃវិទ្យាស្ថានទូលេន សំរាប់គោលនយោបាយ និងច្បាប់ធនធានទឹក; Scott A. Hemmerling, នាយកផ្នែកមនុស្ស ធនធាន និងបច្ចេកវិទ្យានៃវិទ្យាស្ថានធនធានទឹកហ្គាវ; និង Joshua A. Lewis, អ្នកវិភាគការស្រាវជ្រាវ ប្រចាំមជ្ឈមណ្ឌលទូលេន / សេវៀរ សំរាប់ការស្រាវជ្រាវអំពីជីវៈបរិស្ថាន។ របាយការណ៍ពេញលេញអាចរកបាននៅគេហទំព័រ៖ tulanewater.org/papers ។


**សាកលវិទ្យាល័យច្បាប់ទូលេន**

# សេចក្តីផ្តើម៖ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន និង ការតាំងទីថ្មីសំរាប់សហគមន៍

សំរាប់សតវត្សរ៍ខាងមុខ វាទំនងនឹងអាចឃើញការចំណាកស្រុកដោយកត្តាអាកាសធាតុក្នុងទ្រង់ទ្រាយដែលមនុស្សមិនធ្លាប់ដែលជួបប្រទះកន្លងមក។ ការប្រែប្រួលអាកាសធាតុ គឺត្រូវបានរំពឹងថានឹងធ្វើឲ្យមានការប្រែប្រួលលំនាំនៃអាកាសធាតុ ធ្វើឲ្យកើនឡើងកំរិតនីវ៉ូទឹកសមុទ្រ បង្កើនកម្លាំង និងភាពញឹកញាប់នៃខ្យល់ព្យុះដែលជះឥទ្ធិពលទៅដល់ពិភពលោកទាំងមូល។ បញ្ហាទាំងនេះ គឺគ្រប់គ្រាន់ទៅហើយក្នុងការធ្វើឲ្យប្រជាជនធ្វើការផ្លាស់ប្តូរទីលំនៅរបស់ខ្លួន ចំនែកឯសំរាប់ភាគអាគ្នេយ៍នៃរដ្ឋលូអ៊ីស៊ីអាណាវិញ គឺត្រូវជួបប្រទះនឹងបញ្ហាប្រឈមមួយទៀតនៃការការបាក់ឆ្នេរសមុទ្រ។ ថ្វីបើមានផែនការក្នុងការដោះស្រាយបញ្ហាបាក់ឆ្នេរ (Coastal Master Plan 2012) ហើយគម្រោងទាំងអស់នៃផែនការនេះត្រូវបានឧបត្ថម្ភ និងដំណើរការដូចដែលបានគ្រោងក៏ដោយ ក៏នៅតែមានប្រជាជនលូអ៊ីស៊ីអាណាជាច្រើនត្រូវបានបណ្តេញចេញពីកន្លែងរស់នៅរបស់ពួកគេ ដោយមូលហេតុនៃការកើនឡើងនៃកំរិតទឹកសមុទ្រ ខ្យល់ព្យុះ ការសឹករិចរឹល ហើយក៏អាចប្រហែលជាមកពីកត្តាផែនការនេះផងដែរ។

ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនលូអ៊ីស៊ីអាណាគឺមិនអាចចៀសផុតឡើយ ហើយការធានានូវការតាំងទីថ្មីសំរាប់សហគមន៍ដដែលក៏សឹងតែមិនអាចទៅរួចផងដែរ។ ប្រជាជនអាច ព្រមទាំងបានកំពុងធ្វើការផ្លាស់ប្តូរទីលំនៅគ្រប់ពេលវេលា ចំនែកឯតំបន់ឆ្នេរកំពុងបាត់បង់ចំនួនប្រជាជន ហើយទីក្រុងកំពុងត្រូវបានផ្លាស់ប្តូរទៅឆ្ងាយពីមាត់សមុទ្រ និងកាន់តែរួមតូច។ វាត្រូវការឲ្យមានកិច្ចខិតខំប្រឹងប្រែងដែលមានលក្ខណហ្មត់ចត់ និងរៀបរយ ដើម្បីអាចរក្សាសហគមន៍ឲ្យនៅដដែលនៅពេលធ្វើការជម្លៀសពួកគេចេញពីតំបន់មានគ្រោះថ្នាក់។ នោះអាចហៅថា ជាការតាំងទីថ្មីសំរាប់សហគមន៍ ហើយប្រវត្តិសាស្រ្តបានបង្ហាញថា វាគឺពិបាកខ្លាំងណាស់ដើម្បីធ្វើវា។

ការសិក្សានេះសន្និតថា ជម្រើសក្នុងការធ្វើការតាំងទីថ្មីសំរាប់សហគមន៍ក្នុងរដ្ឋលូអ៊ីស៊ីអាណា គឺប្រសើរជាងការផ្លាស់ប្តូរតែទីលំនៅរបស់បុគ្គល ឬប្រជាជនម្នាក់ៗ។ សហគមន៍ទាំងនេះគឺជាសហគមន៍ដែលមានវប្បធម៌មានតម្លៃ មោទនភាព និងខុសប្លែកពីគេ ហើយប្រជាជនមានចំណងស្អិតរមួតទៅនឹងទីកន្លែង និងសហគមន៍របស់ពួកគេ ដូច្នេះការបាត់បង់សហគមន៍របស់ពួកគេ គឺអាចនឹងក្លាយជាសោកនាដកម្មមួយ។ ទោះជាយ៉ាងណាក៏ដោយ ការសម្រេចចិត្តថាតើពួកគេត្រូវធ្វើការតាំងទីថ្មីសំរាប់សហគមន៍ ឬ ត្រូវធ្វើការផ្លាស់ប្តូរតែទីលំនៅរបស់បុគ្គល គឺនៅតែជាជម្រើសរបស់សហគមន៍រៀងៗខ្លួន។

វាគឺមិនដឹងនោះទេ ថាតើអ្នកណានឹងត្រូវជម្លៀសចេញសំរាប់ប្រជាជននៅរដ្ឋលូអ៊ីស៊ីអាណា។ របៀបនៃការតាំងទីថ្មី ការការពារ និងស្តារតំបន់ឆ្នេរ ការប្រែប្រួលអាកាសធាតុ និងលទ្ធផលនៃការកើនឡើងកំរិតទឹកសមុទ្រ ដែលត្រូវបាន ឬមិនត្រូវបានដោះស្រាយ នឹងអាចកំណត់បានពីផ្នែកនៃប្រជាជនដែលរងផលប៉ះពាល់។ វាក៏មិនច្បាស់ផងដែរថាប្រជាជនទាំងនេះគឺជាប្រជាជននៅភាគខាងត្បូងនៃ Interstate លេខ១០ ឬក៏មិនមែន របាយការណ៍នេះបង្ហាញថា ពួកគេគឺជាប្រជាជនដែលក្រីក្រខ្លាំង ជាជនជាតិភាគតិច និងប្រជាជនជនបទដែលពឹងពាក់ទៅលើទឹក និងដី សំរាប់វប្បធម៌ និងការរស់នៅ។

រដ្ឋាភិបាលបានធ្វើការជម្លៀសប្រជាជន និងសហគមន៍ទាំងនេះ ដោយប្រើប្រាស់មូលហេតុផ្សេងៗដូចជាការលើកឡើងថាជាគម្រោងអភិវឌ្ឍន៍សាធារណៈ ក៏ដូចជាដើម្បីបញ្ហាសន្តិសុខជាតិជាដើម និងបានប្រើអំណាចផ្លូវច្បាប់ផ្សេងៗជាច្រើនផងដែរ។ ច្បាប់ទាំងនោះ ជារឿយៗមានប្រសិទ្ធភាពសំរាប់ការផ្លាស់ប្តូរទីលំនៅសំរាប់ប្រជាជន ជាជាងការតាំងទីថ្មី

សំរាប់សហគមន៍ទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ ប្រវត្តិសាស្រ្តបានបង្ហាញថាទាំងកម្មវិធីផ្លាស់ប្តូរទីលំនៅសំរាប់ប្រជាជន និង ការតាំងទីថ្មីសំរាប់សហគមន៍ មានការលំបាកក្នុងការទទួលបានជោគជ័យ។ ការគាំទ្រ និងមូលនិធិទាំងក្នុងតំបន់ និងពីរដ្ឋាភិបាល ជារឿយៗក៏បានបង្ហាញពីភាពមិនគួរទុកចិត្ត និងនិរន្តរភាពផងដែរ ហើយប្រវត្តិនៃការជម្លៀសប្រជាជននៅក្នុងរដ្ឋនេះកន្លងមក ជាទូទៅគឺសុទ្ធតែជាអន្តរាគមន៍ដែលទទួលបរាជ័យសំរាប់រដ្ឋាភិបាល។

គោលនយោបាយដែលឆ្លើយតបទៅនឹងកំណើនគ្រោះថ្នាក់នៅតំបន់ឆ្នេរ ដូចជាការធានារ៉ាប់រងដោយគ្រោះទឹកជំនន់ដែលមានការឧបត្ថម្ភពីរដ្ឋាភិបាល និង ផែនការមេតំបន់ឆ្នេរឆ្នាំ ២០១២ របស់រដ្ឋលូអ៊ីស៊ីអាណា បានមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការធ្វើឲ្យមានស្ថេរភាពការតាំងទីលំនៅរបស់ប្រជាជន និងការចំណាកស្រុកក្នុងតំបន់។ អត្រាកំណើននៅក្នុងកម្មវិធីធានារ៉ាប់រងគ្រោះទឹកជំនន់ជាតិ (NFIP) គឺទំនងជានឹងមានភាពខុសគ្នារវាងសមាមាត្រសំរាប់ប្រជាជនខ្សត់ខ្សោយ។ នេះរួមមានដូចជាប្រជាជនជនជាតិអាមេរិកកាត់អាហ្វ្រិក អាស៊ី និងប្រជាជនដែលនិយាយភាសាអេស្ប៉ាញនៅតំបន់ទីក្រុងនៃរដ្ឋញូអរលៀន (New Orleans) និង ជនជាតិដើមអាមេរិកដែលរស់នៅភាគខាងត្បូងឡាហ្វូសេ (Lafourche) និង សហគមន៍ថេរេប៊ីន (Terrebonne Parishes)។ ផែនការមេតំបន់ឆ្នេរ នឹងផ្តល់ឲ្យនូវការការពាររចនាសម្ព័ន្ធដល់គ្រួសារជាង ៨៦ ភាគរយដែលកំពុងរងគ្រោះនៅរដ្ឋលូអ៊ីស៊ីអាណា។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍មួយចំនួនតូចដែលរស់នៅតាមតំបន់ឆ្នេរដាច់ស្រយាល ដែលការការពាររចនាសម្ព័ន្ធពុំទាន់ទៅដល់ គឺនៅតែជាមុខសញ្ញាប្រឈមនឹងគ្រោះថ្នាក់ធម្មជាតិ និងហានិភ័យជាច្រើន។ ជាពិសេស ដែលត្រូវកត់សម្គាល់ម្តងទៀត គឺជនជាតិដើមអាមេរិកដែលរស់នៅភាគខាងត្បូងឡាហ្វូសេ (Lafourche) និង សហគមន៍ថេរេប៊ីន (Terrebonne Parishes)។

ប្រជាជនដែលកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់ភាគច្រើនគឺប្រជាជនខ្សត់ខ្សោយ ហើយប្រវត្តិសាស្រ្តក្នុងតំបន់បានបន្សល់ទុកនូវភាពមិនជឿទុកចិត្តទៅលើកម្មវិធីរដ្ឋាភិបាលក្នុងការអាចជួយដោះស្រាយបញ្ហាដល់សហគមន៍លូអ៊ីស៊ីអាណា។ បញ្ហាទាំងនេះរួមបញ្ចូលគ្នាបានបង្កឲ្យមានការលំបាកជាខ្លាំងក្នុងការជម្លៀសប្រជាជនចេញពីតំបន់គ្រោះថ្នាក់ ព្រមទាំងអនុញ្ញាតឲ្យពួកគេអាចរក្សាសហគមន៍ និងវប្បធម៌របស់ពួកគេឲ្យនៅដដែល។

## <u>យន្តការផ្លូវច្បាប់សំរាប់កិច្ចខិតខំប្រឹងប្រែងមុនការផ្លាស់ប្តូរទីតាំងនៅសហរដ្ឋអាមេរិក</u>

ក្នុងប្រវត្តិសាស្រ្តនៃប្រទេសអាមេរិក ប្រជាជនបានធ្វើការផ្លាស់ប្តូរទីតាំងក្រោមស្ថានការផ្សេងៗជាច្រើន ដែលខ្លះគឺជារឿងគួរឲ្យអាម៉ាស់ និងខ្លះជារឿងថ្លៃថ្នូរប្រពៃ ឯខ្លះទៀតគឺជាការឆ្លើយតបទៅនឹងបញ្ហា និងខ្លះគឺជាការប្រុងប្រយ័ត្នទុកជាមុន។ តាមរយៈស្ថានការទាំងអស់នេះ វាជាមេរៀនដែលអាចរៀនបានអំពីអ្វីដែលអាច និងគួរធ្វើ និង អ្វីដែលមិនអាច និងមិនគួរធ្វើ ក្នុងការធ្វើការតាំងទីថ្មីសំរាប់សហគមន៍។ ជាទូទៅ ការផ្លាស់ប្តូរទីតាំងត្រូវបានធ្វើឡើងក្នុងនាមជាការងារសាធារណៈ ឬជាការឆ្លើយតបទៅនឹងគ្រោះថ្នាក់ជាក់ស្តែង។ តម្រូវការឲ្យមានគោលនយោបាយក្នុងការផ្លាស់ប្តូរទីតាំងគឺជារឿយៗនៅតែត្រូវបានព្រងើយកន្តើយ ហើយប្រជាជនត្រូវបានទុកឲ្យសម្រេចចិត្តដោយខ្លួនឯង ដែលនេះបានក្លាយជាកត្តារាំងស្ទះសំរាប់ប្រជាជន ក៏ដូចជាសហគមន៍របស់ពួកគេ និងសង្គមទាំងមូល។

ការតាំងទីលំនៅថ្មីសំរាប់សហគមន៍ គឺជាការងារដែលលំបាកខ្លាំងមួយ។ សមត្ថភាព ជាពិសេសឆន្ទៈក្នុងការផ្លាស់ប្តូរទីតាំងសហគមន៍ទាំងមូល ដោយរក្សាលក្ខណៈដើមរបស់ពួកគេ គឺពិបាកខ្លាំងក្នុងការសម្រេចឲ្យបាន។ មិនដូចភាពជាបុគ្គលនោះទេ សហគមន៍មួយអាចមិនមែនអង្គភាពដែលស្របច្បាប់នៅឡើយ (លុះត្រាតែជាក្រុមជនជាតិភាគតិចដែល

ត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាល)។ ដូច្នេះកិច្ចខិតខំប្រឹងប្រែងដែលបានរៀបចំ គឺជាធម្មតាផ្តោតតែទៅលើការផ្លាស់ប្តូរទីតាំងសំរាប់បុគ្គល ឬគ្រួសារ មិនមែនសហគមន៍ទាំងមូលនោះទេ។

សូម្បីកម្មវិធីដែលជួយជ្រោមជ្រែងក្នុងការផ្លាស់ប្តូរទីតាំងសំរាប់បុគ្គល ក៏ត្រូវការការគាំទ្រផ្នែកនយោបាយ ហិរញ្ញវត្ថុ និងប្រជាប្រិយភាពដើម្បីសម្រេចបានជោគជ័យផងដែរ ចុះទំរាំការតាំងទីថ្មីសំរាប់សហគមន៍ទាំងមូល។ ការស្រាវជ្រាវអំពីកិច្ចខិតខំប្រឹងប្រែងកន្លងមកនៅភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណា បានបង្ហាញពីភាពលំបាកក្នុងការធ្វើឲ្យជោគជ័យនូវការតាំងទីថ្មីដល់សហគមន៍ ក៏ដូចជាតម្លៃនៃវប្បធម៌ និងនយោបាយដែលនឹងត្រូវលះបង់ ប្រសិនបើការខិតខំទាំងនេះមិនបានឆ្លើយតបទៅតាមបំណងប្រាថ្នារបស់សហគមន៍។

## កិច្ចខិតខំប្រឹងប្រែងក្នុងការតាំងទីលំនៅថ្មី និងការផ្លាស់ប្តូរទីតាំងកន្លងមកនៅភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណា

ការផ្លាស់ប្តូរទីតាំង និងការជម្លៀសសហគមន៍ជាក់លាក់ក្នុងតំបន់ឆ្នេររដ្ឋលូអ៊ីស៊ីអាណា ត្រូវបានធ្វើឡើងទៅតាមលំនាំផ្លាស់ប្តូរនៃគ្រោះទឹកជំនន់ គោលនយោបាយសាធារណៈដែលឆ្លើយតបទៅនឹងបញ្ហា និងយន្តការផ្លូវច្បាប់ ឬស្ថាប័នដែលបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ និង កម្មវិធីរបស់រដ្ឋាភិបាលដែលសមស្របទៅតាមដែនជាក់ស្តែង។ រឿងរ៉ាវទាក់ទិននឹងការមិនពេញចិត្ត និង ការប្រឆាំងទៅនឹងគោលនយោបាយផ្លាស់ប្តូរទីតាំងកើតមានតាំងពីយូរណាស់មកហើយ។ ប្រធានបទដែលសំខាន់នៅក្នុងឧទាហរណ៍ គឺសំដៅដល់ការគ្រប់គ្រងវិធីសាស្រ្តក្នុងការផ្លាស់ប្តូរទីតាំងមិនបានល្អ ដែលជាហេតុបណ្តាលឲ្យមានការបាត់បង់ជំនឿទុកចិត្តរវាងប្រជាពលរដ្ឋ និងអាជ្ញាធរទទួលបន្ទុកកម្មវិធីការតាំងទីលំនៅថ្មី។ ចំពោះករណីខ្លះ ការបាត់បង់ទំនុកចិត្តបន្តរហូតដល់ប៉ុន្មានជំនាន់ឯនោះ ដូច្នេះហើយទើបកម្មវិធីគ្រប់គ្រងគ្រោះទឹកជំនន់ និងការស្តារតំបន់ឆ្នេរបច្ចុប្បន្ន កំពុងប្រឈមនឹងនយោបាយចម្រូងចម្រាសដែលបង្កើតឡើងជាច្រើនទសវត្សរ៍មកហើយ ដោយសារការមិនបានធ្វើតាមការសន្យា បញ្ហាក្នុងការទំនាក់ទំនង និងអំពើខុសឆ្គងរបស់មន្រ្តីសាធារណៈខ្លួនឯងតែម្តង។

## ការវិភាគប្រជាសាស្រ្តនៃប្រជាជនដែលអាចប្រឈមមុខនឹងការផ្លាស់ប្តូរទីលំនៅនៅភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណា

បញ្ហាប្រឈមនឹងបរិស្ថានបច្ចុប្បន្នក្នុងការតាំងទីលំនៅតំបន់ឆ្នេររដ្ឋលូអ៊ីស៊ីអាណាបានបង្កជាក្តីកង្វល់ដល់សង្គមភ្លាមៗ និងសំខាន់ចាំបាច់ជាខ្លាំង។ ពីព្រោះតែអត្រា និងភាពតានតឹងនៃគ្រោះធម្មជាតិចេះតែបន្តកើនឡើង ដូច្នេះការចំណាកស្រុករបស់ប្រជាជនក៏កាន់តែកើនឡើងទៅតាមនោះផងដែរ។ សំរាប់ការសិក្សានេះ យើងធ្វើការផ្តោតទៅលើកត្តាចំបងពីរនៃការចំណាកស្រុកដោយកត្តាធម្មជាតិ រួមមានភាពគ្រោះថ្នាក់ និងហានិភ័យជាក់ស្តែង ព្រមទាំងគោលនយោបាយឆ្លើយតបទៅនឹងគ្រោះថ្នាក់ទាំងនេះ។ គោលនយោបាយឆ្លើយតបទាំងនេះ ផ្តោតសំខាន់ទៅលើការកាត់បន្ថយហានិភ័យតាមរយៈការការពារ និងការស្តារតំបន់ឆ្នេរ ក៏ដូចជាអនុញ្ញាតឲ្យប្រជាពលរដ្ឋបន្តរស់នៅក្នុងកំរិតហានិភ័យបែបនេះ តាមរយៈគោលនយោបាយធានារ៉ាប់រងគ្រោះទឹកជំនន់។ កត្តាបរិស្ថានបង្ហាញថា ចំនួននៃប្រជាជនជាក់លាក់ ជួបប្រទះកំរិតខុសៗគ្នានៃហានិភ័យ ដូច្នេះវាជាគោលនយោបាយឆ្លើយតបដែលអាចនឹងកំនត់ពីកំរិតនៃស្ថេរភាពប្រជាជនបាន។

ការផ្លាស់ប្តូរទីលំនៅសំរាប់ប្រជាជន ឬ ការផ្លាស់ប្តូរទីតាំងសំរាប់សហគមន៍ ជាទូទៅត្រូវបានអ្នករៀបចំផែនការ និងអ្នកបង្កើតគោលនយោបាយចាត់ទុកថាជាជម្រើសចុងក្រោយ។ អាជ្ញាធរស្តារ និងការពារតំបន់ឆ្នេររដ្ឋលូអ៊ីស៊ីអាណាបានកត់សម្គាល់ថា មានភាគរយតិចតួចណាស់នៃតំបន់ងាយរងគ្រោះ ដែលត្រូវបានពិចារណាឲ្យប្រជាជនចំណាកស្រុក ឬ ការទទួលយកដោយស្ម័គ្រចិត្ត ខណៈដែលភាគច្រើនគឺយើងប្រើប្រាស់ជម្រើសផ្សេងទៅវិញដូចជាការប្រើប្រាស់អាគារខ្ពស់ៗ និងអាចការពារគ្រោះទឹកជំនន់។ មជ្ឈមណ្ឌល Center for Planning Exellence (CPEX) បានកត់សម្គាល់ផងដែរថា ការផ្លាស់ប្តូរទីលំនៅគឺជាវិធីសាស្រ្តចុងក្រោយផងដែរ ហើយចាត់ទុកការផ្លាស់ប្តូរទីតាំងសំរាប់សហគមន៍ទាំងមូល គឺជាផែនការយុទ្ធសាស្រ្តសំខាន់ចាំបាច់សំរាប់តំបន់ប៉ៃលតាមីស៊ីស៊ីបពី និងតំបន់ទំនាបនៃច្រាំងទន្លេនៅភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណា។

ឥទ្ធិពលវប្បធម៌ និងសង្គមនៃចំណាកស្រុកចេញពីតំបន់ប្រជុំជនដែលមានការអភិវឌ្ឍន៍ នឹងនាំមកនូវបណ្តុំផលប៉ះពាល់ដែលមានលក្ខណៈខុសគ្នាពីចំណាកស្រុកដែលចេញពីតំបន់ជនបទ។ ខណៈដែលមានការសិក្សាស្រាវជ្រាវតិចតួចអំពីចំណាកស្រុកដែលបណ្តាលមកពីកត្តាបរិស្ថានចេញពីតំបន់ប្រជុំជន វាប្រាកដណាស់ថាមានភាពខុសគ្នារវាងចំណាកស្រុកធ្វើឡើងនៅក្នុងទីប្រជុំជន ឬចេញក្រៅពីទីប្រជុំជន និង ចំណាកស្រុកពីទីជនបទទៅទីប្រជុំជន ដែលទាំងនេះត្រូវបានចាត់ទុកថា ស្ថិតនៅក្នុងការសិក្សាអំពីចំណាកស្រុកបណ្តាលមកពីកត្តាបរិស្ថាន។ បញ្ហាជាក់លាក់ពាក់ព័ន្ធនឹងចំណាកស្រុកចេញពីទីក្រុងត្រូវបានសិក្សាក្នុងបរិបទផ្សេងទៀត រួមមានបញ្ហាដូចជាៈ

១. លំនៅដ្ឋានដែលទំនេរ
២. អ្នកជិតខាងដែលញាំញី
៣. ការផ្លាស់ប្តូរទំរង់ប្រជាសាស្រ្ត ពីព្រោះតែមានប្រជាជនថ្មីចូលមករស់នៅតំបន់ដែលមានហានិភ័យ
៤. មូលដ្ឋានអត្រាពន្ធថយចុះ ពាក់ព័ន្ធនឹងថ្លៃក្នុងការរក្សារចនាសម្ព័ន្ធឲ្យនៅដដែល

សហគមន៍ រដ្ឋ និងរដ្ឋាភិបាល ដែលពិចារណាក្នុងការអនុវត្តកម្មវិធីផ្លាស់ប្តូរទីតាំងយុទ្ធសាស្រ្តនៅតំបន់ឆ្នេររដ្ឋលូអ៊ីស៊ីអាណា ត្រូវពិចារណាពីកត្តាផ្សេងៗផងដែរ នៅពេលដែលមានបំណងចង់កាត់បន្ថយផលប៉ះពាល់ ដែលបណ្តាលមកពីការចំណាកស្រុករបស់ប្រជាជន ហើយចំនុចសំខាន់នោះគឺស្ថានភាពសង្គមសេដ្ឋកិច្ច និងទំរង់ប្រជាសាស្រ្តដែលជាផ្នែករបស់សហគមន៍កំពុងមានហានិភ័យ។ អាជ្ញាធរផ្លាស់ប្តូរទីលំនៅគួរតែយល់ដឹងពីភាពខុសគ្នានៅក្នុងរចនាសម្ព័ន្ធគ្រួសារដែលសហគមន៍ជនជាតិភាគតិចមាន ក៏ដូចជាបុគ្គលិកលក្ខណៈទីក្រុង និងជនបទរបស់សហគមន៍ទាំងឡាយ។

## សំយោគវិធីសាស្រ្តទាំងបីៈ ការពិភាក្សា និង សេចក្តីសន្និដ្ឋាន

ប្រវត្តិនៃការផ្លាស់ប្តូរទីតាំងសំរាប់សហគមន៍នៅសហរដ្ឋអាមេរិក និងភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណា បានបង្ហាញពីលទ្ធភាពជាច្រើនផ្សេងៗគ្នា ប៉ុន្តែមានតិចតួចដែលទទួលបានជោគជ័យ។ យន្តការ និងផែនការក្នុងការការពារសហគមន៍តំបន់ឆ្នេរហាក់ដូចជាមិនមាននិរន្តរភាព មិនទទួលបានការឧបត្ថម្ភ ភាពមិនជាក់ស្តែង និងមិនគ្រប់គ្រាន់។ ក្នុងទស្សនៈអភិរក្សសហគមន៍ទាំងនេះ វាគឺជាស្ថានការដែលមិនអាចយកជាការបាននោះឡើយ ក្នុងការដែលទុកឲ្យប្រជាជនដែលងាយរងគ្រោះឲ្យបន្តរស់នៅនៅតំបន់ងាយប្រឈមនឹងគ្រោះថ្នាក់បែបនេះ។

មេរៀនដែលយើងអាចរៀនបានពីប្រវត្តិនៃការផ្លាស់ប្តូរទីលំនៅ និងការផ្លាស់ប្តូរទីតាំងសហគមន៍ទូទាំងសហរដ្ឋអាមេរិក និងភាគអាគ្នេយ៍រដ្ឋលូអ៊ីស៊ីអាណាគឺថា គម្រោងទាំងនោះមិនមានប្រសិទ្ធភាព។ បើទោះជារដ្ឋាភិបាលមានអំណាចអាចសម្រេចជម្លៀសប្រជាពលរដ្ឋអាមេរិកក៏ដោយ ក៏ពួកគេជារឿយៗមិនមានឆន្ទៈក្នុងការធ្វើនោះឡើយ។ នៅពេលដែល

កម្មវិធីត្រូវបានអនុវត្ត វាទាមទារឲ្យមានការជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុ និងនយោបាយដែលមាននិរន្តរភាពដើម្បីបន្តដំណើរការទៅបានក្នុងកំឡុងពេលកម្មវិធី។ បន្ថែមពីនេះ ដើម្បីឲ្យកម្មវិធីផ្លាស់ប្តូរទីលំនៅ ឬការផ្លាស់ប្តូរទីតាំងសហគមន៍ទទួលបានជោគជ័យជាមួយនឹងប្រជាជនដែលនឹងត្រូវជម្លៀស យើងចាំបាច់ត្រូវទទួលបានការគាំទ្រ និងការចូលរួមរបស់ពួកគេក្នុងដំណើរការសម្រេចចិត្តតាំងពីដំបូងតែម្តង។ ភាគីនីមួយៗដែលមានតួនាទីក្នុងកម្មវិធីផ្លាស់ប្តូរទីលំនៅ ឬការផ្លាស់ប្តូរទីតាំង ត្រូវតែវិនិយោគ និងចាប់អារម្មណ៍ក្នុងការបំពេញតួនាទីរបស់ខ្លួន។

ជាមួយនឹងការលើកលែងដែលគួរឲ្យកត់សម្គាល់សំរាប់សហគមន៍ជាក់លាក់មួយចំនួន(ជាពិសេសជនជាតិដើមអាមេរិក) ម្ចាស់ដីតំបន់ឆ្នេរ និងអ្នកពាក់ព័ន្ធជាច្រើនផ្សេងទៀត គឺមិនមានឆន្ទៈក្នុងការផ្តួចផ្តើម ឬចូលរួមក្នុងដំណើរការនយោបាយ និងការសន្ទនានោះទេ ដែលទាំងនេះធ្វើឲ្យលទ្ធផលនៃការផ្លាស់ប្តូរទីលំនៅរបស់ពួកគេប្រាកដជាមិនបានជោគជ័យ ជាពិសេសជាមួយនឹងមូលនិធិការពារទឹកជំនន់របស់រដ្ឋាភិបាល និងរដ្ឋ។ រឿងចុងក្រោយដែលមេដឹកនាំ សហគមន៍ និងសកម្មជនចង់ធ្វើនោះគឺសូមចុះចាញ់ និងបោះបង់ផ្ទះសំបែង និងដី ដែលពួកគេបានរស់នៅជាច្រើនជំនាន់។ ហើយរឿងដែលអ្នកបង្កើតគោលនយោបាយចង់ធ្វើវិញនោះគឺ រុញច្រានកម្មវិធីផ្លាស់ប្តូរទីលំនៅដែលមិនមានប្រជាប្រិយភាពនោះទៅមុខ ហើយដែលសឹងតែគ្មានឱកាសនឹងទទួលជោគជ័យ បើទោះជាទទួលបានការឧបត្ថម្ភថវិការគ្រប់គ្រាន់ក៏ដោយ។ ដោយសារប្រវត្តិនៃកិច្ចខិតខំប្រឹងប្រែងមួយរបស់រដ្ឋាភិបាលនៅក្នុងតំបន់ គឺកម្មវិធី Road Home (ផ្លូវផ្ទះ) បានបង្កឲ្យមានការបាត់បង់ជំនឿចិត្តដ៏ធ្ងន់ធ្ងរពីប្រជាជនទៅលើសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការកំនត់នូវអ្វីដែលត្រូវធ្វើដើម្បីផ្តួចផ្តើមការតាំងទីថ្មីសំរាប់សហគមន៍។ ជាថ្មីម្តងទៀត ជម្រើសដែលងាយស្រួលបំផុតសំរាប់អ្នកពាក់ព័ន្ធទាំងឡាយគឺ ការមិនធ្វើអ្វីទាំងអស់។ វា គឺដូចត្រូវបានកំនត់រួចទៅហើយ ។ វាក៏ជាការធ្វើឲ្យខ្ចាត់ខ្ចាយប្រជាជនដោយចាកចេញពីសហគមន៍តំបន់ឆ្នេរទៅកាន់ទីកន្លែងដែលយើងមិនដឹងថាទៅទីណាខ្លះ។

ដូច្នេះតើវានឹងទុកឲ្យសហគមន៍ទាំងនេះទៅជាយ៉ាងណាវិញ? ចាប់ពីពេលនេះទៅ អ្នកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមក្នុងការធ្វើបច្ចុប្បន្នភាពផែនការមេតំបន់ឆ្នេររដ្ឋលូអ៊ីស៊ីអាណា ដើម្បីធានាថាកិច្ចខិតខំប្រឹងប្រែងដែលមិនទាន់មានលក្ខណៈសមស្រប ត្រូវធ្វើឲ្យមានរចនាសម្ព័ន្ធច្បាស់លាស់ និងការឧបត្ថម្ភគ្រប់គ្រាន់ដើម្បីបំរើដល់ប្រជាជនដែលត្រូវការកម្មវិធីនេះបំផុត។ អ្នកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមក្នុងការកំនត់ពីអនាគតរបស់កម្មវិធីធានារ៉ាប់រងគ្រោះទឹកជំនន់ជាតិ (NFIP) ។ តើវានឹងបន្តទៀតដែរឬទេ? តើវានឹងអាចដោះស្រាយបញ្ហាបានដែរឬទេ? តើថវិកាគ្រប់គ្រាន់ដែរឬទេ? តើវានឹងគ្របដណ្តប់ដល់ប្រជាជនណាខ្លះ? តើអ្វីខ្លះដែលនឹងត្រូវពិចារណានៅពេលធ្វើការកំនត់ផែនទីទឹកជំនន់? សំនួរទាំងនេះនឹងមិនអាចឆ្លើយបាននោះឡើយ ប្រសិនបើមិនមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ដែលមកពីសហគមន៍តំបន់ឆ្នេរ។

---

## ការសិក្សានេះសម្រេចទៅបានជាមួយនឹងការគាំទ្រពី៖

វិទ្យាស្ថានសូមថ្លែងអំណរគុណចំពោះការគាំទ្រពីវិទ្យាស្ថានធនធានទឹកហ្គាវ (The Water Institute of the Gulf) មជ្ឈមណ្ឌលលំនៅដ្ឋានស្តុកខូម (Stockholm Resilience Centre) មជ្ឈមណ្ឌលទូលេន / សេវៀរ សំរាប់ការស្រាវជ្រាវអំពីជីវៈបរិស្ថាន (Tulane/Xavier Center for Bioenvironmental Research) និងជំនួយហិរញ្ញវត្ថុពីអុក្សហ្វាមអាមេរិក (Oxfam America) ដែលជួយដល់ការរៀបចំរបាយការណ៍ និងសេចក្តីសង្ខេបនេះ។ របាយការណ៍នេះមិនសំដៅ ឬបង្ហាញពីមតិយោបល់របស់អុក្សហ្វាមអាមេរិកនោះឡើយ ហើយរាល់ការទទួលខុសត្រូវទាំងអស់ទៅលើខ្លឹមសារនៃរបាយការណ៍គឺជាបន្ទុករបស់វិទ្យាស្ថានទូលេនសំរាប់គោលនយោបាយ និងច្បាប់ធនធានទឹក និង អ្នកនិពន្ធ។